# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

===================

# ក្រុមហ៊ុន ធី អ័រ ស៊ី អេ ហ្គាម៉ិន

## កិច្ចព្រមព្រៀង

ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០២០ នៅក្រុមហ៊ុន ធី អ័រ ស៊ី អេ ហ្គាម៉ិន បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពអ្នកស្រី សុខ ទាំង ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរ កិច្ចសន្យាការងារមួយរយៈដោយមូលហេតុដោយសារតែក្រុមហ៊ុនត្រូវបានភ្ញៀវផ្អាកការបញ្ជាទិញសម្លៀកបំពាក់ បណ្តាលឲ្យសង្វាក់ផលិតកម្មមិនអាចដំណើរការទៅមុខបានក្នុងរយៈ០២ខែ។

សមាសភាពចូលរួម៖

1- ភាគីតំណាងក្រុមហ៊ុន

- លោក Zhou Yong — តំណាងនាយករោងចក្រ
- លោកស្រី សុខ ទាំង — ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោក ជៀម កុសល — ជាប្រធានសហជីប
- លោក ពេន សារីត — ជាប្រធានសហជីប
- លោក ប៉ុល រតនា — ជាប្រតិភូបុគ្គលិក
- លោកស្រី នៅ មួយ — ជាប្រតិភូបុគ្គលិក
- លោកស្រី ហាន ចន្ធូ — ជាប្រតិភូបុគ្គលិក
- លោក សំ ពិសិដ្ឋ — ជាប្រតិភូបុគ្គលិក

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៣២៩នាក់ ក្នុងចំណោមកម្មករសរុបចំនួន ៣២៩នាក់ ក្នុងរយៈពេល២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្តល់ទៅតាមសេចក្តីណែនាំលេខ០៤៥/២០ របស់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៧ មេសា ឆ្នាំ ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាសគ្រឹះស្ថានក្នុងវិស័យការងារ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារកូវីដ-១៩។

3- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៣:២០នាទី នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃច័ន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ពស២៥៦៣

ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

| | |
|---|---|
| បានឃើញនឹងឯកភាព | បានឃើញនឹងឯកភាព |
| តំណាង ក្រុមហ៊ុន | តំណាងកម្មករ |
| សុខ ទាំង | ១. លោក ជៀម កុសល ជាប្រធានសហជីប |
| | ២. លោក ពេន សារីត ជាប្រធានសហជីប |
| | ៣. លោក ប៉ុល រតនា ជាប្រតិភូបុគ្គលិក |
| | ៤. លោកស្រី ឆៅ មួយ ជាប្រតិភូបុគ្គលិក |
| | ៥. លោកស្រី ហាន ចន្ធូ ជាប្រតិភូបុគ្គលិក |
| | ៦. លោក សំ ពិសិដ្ឋ ជាប្រតិភូបុគ្គលិក |